ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...២១៧១៩...អពដ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទបញ្ចប់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនម្ចាស់យានយន្តទាំងអស់ ដែលមានកាតព្វកិច្ចបង់ពន្ធលើមធ្យោ-បាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ មេត្តាជ្រាបថា អនុលោមតាមប្រកាសលេខ ៥៥៧ សហវ.ប្រក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ នឹងត្រូវបិទបញ្ចប់ជាស្ថាពរ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ នាវេលាម៉ោង ៥:០០ នាទីរសៀល ។ ទន្ទឹមនឹងនេះ ក៏នៅសង្កេតឃើញមានម្ចាស់យានយន្តមួយចំនួនទៀតនៅបន្តអញ្ជើញមកប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមធនាគារកាណាឌីយ៉ា ក.អ ឬនៅធនាគារអេស៊ីលីដា ភីអិលស៊ី ឬនៅធនាគារវឌ្ឍនៈ ឬនៅធនាគារកម្ពុជាសាធារណៈ នៅក្នុងថ្ងៃចុងបញ្ចប់នៃការបិទប្រកាសបង់ពន្ធនេះ។

ក្នុងករណីខកខានមិនបានបង់ពន្ធទាន់ពេលវេលាតាមការកំណត់ខាងលើ ម្ចាស់យានយន្តក៏អាចបន្តអញ្ជើញទៅបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ បានផងដែរ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមធនាគារកាណាឌីយ៉ា ក.អ ឬនៅធនាគារអេស៊ីលីដា ភីអិលស៊ី ឬនៅធនាគារវឌ្ឍនៈ ឬនៅធនាគារកម្ពុជាសាធារណៈ ដោយត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារមានក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ម្ចាស់យានយន្តទាំងអស់នឹងរួសរាន់ទៅប្រកាសបង់ពន្ធបានគ្រប់ៗគ្នា និងបានទាន់ពេលវេលា ស្របតាមបទប្បញ្ញត្តិនៃច្បាប់ធរមាន ដើម្បីចៀសវាងនូវការឃាត់យានយន្តតាមដងផ្លូវតម្រូវឱ្យបង់ពន្ធ ដែលអាចនាំឱ្យមានការប៉ះពាល់ការធ្វើដំណើរ និងអាចកើតមាននូវបាតុភាពអសកម្មដោយប្រការណាមួយ។

*រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១*
*ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា គ.ស ២០១៧*

អគ្គនាយកដ្ឋានពន្ធដារ